ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៥៤
ចុះថ្ងៃទី១៩ - ៨ - ៥៩

សាលដីកា
លេខ: ៣៤
ចុះថ្ងៃទី២៧ - ១០ - ៥៩

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៥៩ ដោយមានសមាសភាពដូចតទៅ :

១ - ឯកឧត្តម ឌិត មុន្នី ជាប្រធាន
២ - លោក ឈឹម ស៊ីផល ជាចៅក្រម
៣ - លោក សោម សិរីវង្ស ជាចៅក្រម
៤ - លោក ប្រាក់ គីមសាន ជាចៅក្រមរបាយការណ៍
៥ - លោក យស់ សួនខឿន ជាចៅក្រម
លោក ប៉ុល វណ្ណា ក្រឡាបញ្ជី
តំណាងឧត្តមអយ្យការលោក សាយ សារី ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ១៦៤ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៥៩ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ ៥៤ ចុះថ្ងៃទី ១៩ ខែ សីហាឆ្នាំ១៩៥៩ របស់តុលាការកំពូល

ពីបទ : ឆបោក ប្រព្រឹត្តកាលពីថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ១៩៥៥ នៅក្រុងភ្នំពេញ

- ជនជាប់ចោទឈ្មោះ ព្រាប ឈុនហោងជី " ម្ចាស់បណ្តឹងសាទុក្ខ "ភេទប្រុសអាយុ៣១ឆ្នាំ ជាតិ ខ្មែរ មុខរបរនៅផ្ទះ ទីលំនៅសព្វថ្ងៃផ្ទះលេខ ២៦៤បេ ក្រុម៧ ផ្លូវលេខ ១០៧ សង្កាត់បឹងព្រលឹត ខណ្ឌ ៧មករា ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ ព្រាប សាន " ស " ម្តាយឈ្មោះស៊ឹម យ៉ាន " រ " ប្រពន្ធឈ្មោះ ជា អ៊ឹម មានកូន ០២ នាក់ ។ ទោសពីមុនគ្មាន នៅក្រៅឃុំ ។
- មេធាវីការពារលោក សុង ផេង
- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ កៅ ដារ៉ា " ជាចុងបណ្តឹងសាទុក្ខ "ភេទស្រី អាយុ៤១ ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅសព្វថ្ងៃផ្ទះលេខ ៤៦៩ ក្រុម៥ សង្កាត់ចតុមុខ ផ្លូវស៊ីសុវត្ថិ -/.

ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ កៅហ៊ាន " រ " ម្តាយឈ្មោះ លឹម សួរ " ស " ប្តីឈ្មោះ-ខេង សារ៉ុន មានកូន០៤នាក់ ។

- តាមបណ្តឹងសាទុក្ខលេខ ៤៩ ចុះថ្ងៃទី២៧-៥-៩៩ របស់លោក សុក ផេង " មេធាវីការពារជនជាប់ចោទ " ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ១៦១ ចុះថ្ងៃទី ២៦-៥-៩៩របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- តាមពាក្យបណ្តឹងចុះថ្ងៃទី ០៦-៣-៩៨ របស់ឈ្មោះ កៅ ដារ៉ា ប្តឹងពីឈ្មោះព្រាប ឃុន ហៅ ជី ដែលបានបោកយកប្រាក់ខ្លួនចំនួន២០.០០០ " ពីរម៉ឺនដុល្លារអាមេរិក " កាលពីថ្ងៃទី ២៨-៩-៩៥ រួចគេចបាត់ពីកន្លែងលក់ដូររហូតដល់សព្វថ្ងៃ ។

- តាមចម្លើយជនជាប់ចោទឈ្មោះ ព្រាប ឃុន ហៅជី ឆ្លើយថា នៅឆ្នាំ ១៩៩២ ឬ ១៩៩៣ ខ្លួនរកស៊ីលក់ខោអាវនៅតូបលេខ ២១២ជ១ជាន់ទី១ នៅផ្សារអូឡាំពិក ហើយក៏គ្មានមុខរបរផ្សេងពុំដែរ ក្នុងការរកស៊ីនេះមានគ្នា៣នាក់ គឺម្តាយខ្លួនឈ្មោះ ស៊ឹម យ៉ាន ខ្លួននិងប្អូនស្រីឈ្មោះ ព្រាប ហួង ។ ខ្លួនចេញពីផ្សារអូឡាំពិកឈប់លក់ដូរចាប់ពីខែ ១១-៩៤ ដោយខ្លួនទៅធ្វើចំការ ។ នៅឆ្នាំ ១៩៩៥ ខ្លួនមិនបានរកស៊ីដូរលុយនៅផ្សារអូឡាំពិកទេ ។ ខ្លួនមិនដែលស្គាល់ឈ្មោះ កៅ ដារ៉ា ទេ ។

- បានឃើញដីកាសំរេចលេខ ១៧៤៣តព្រ ចុះថ្ងៃទី ២៣-៤-៩៨ របស់ចៅក្រមស៊ើបអង្កេត ដែលមានខ្លឹមសារថា: បដិសេធពាក្យសុំដោះលែងជនល្មើសកោយនៅក្រៅឃុំជាបណ្តោះអាសន្ន និងលើកលែងចោទប្រកាន់ របស់ឈ្មោះ សុក ផេង ជាមេធាវីរបស់ជនល្មើសឈ្មោះ ព្រាប ឃុន ហៅជី ភេទប្រុស អាយុ ៣១ ឆ្នាំជាតិខ្មែរ ពីបទឆបោកទ្រព្យសម្បត្តិប្រជាជន ប្រព្រឹត្តនៅក្រុងភ្នំពេញកាលពីថ្ងៃទី ២៨-៩-៩៥ ទុកជាអសារបង់ ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ ១៣ "ឃ" ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៩៨ របស់លោក សុង ផេង ជាមេធាវីជនល្មើស ដែលប្តឹងតវ៉ាពីដីកាសំរេចលេខ ១៧៤៣តព្រ ចុះថ្ងៃទី ២៣-៤-៩៨ របស់ចៅក្រមស៊ើបអង្កេត លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា :

១ - ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៨-៤-៩៨ របស់លោកមេធាវី សុក ផេង ទុកត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោលដោយទាល់គតិច្បាប់ ។

២ - តម្កល់ដីកាសំរេចលេខ១៧៤៣តព្រ ចុះថ្ងៃទី ២៣-៤-៩៨ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ១៦១ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ដែលបានសំរេច :

១ - ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៨-៤-៩៨ របស់លោក សុក ផេង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាល់និងគតិច្បាប់ ។

២ - តម្កល់ដីកាសំរេចលេខ ១៧៤៣តព្រ ចុះថ្ងៃទី២៣-៤-៩៨ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល ។/

- បានឃើញបណ្តឹងសាទុក្ខលេខ ៤៩ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៩ របស់លោក សុក ផេង ជាមេធាវីជនជាប់ចោទ ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ១២១ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញពាក្យសុំដកបណ្តឹងសាទុក្ខ ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ១៩៩៩ របស់ជនជាប់ចោទឈ្មោះ ព្រាប ឈុន ជាម្ចាស់បណ្តឹងសាទុក្ខ ។

- បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា : តំណាងមហាអយ្យការគ្មានយោបល់អ្វីបន្ថែមទៀតទេ សូមរក្សាសេចក្តីសន្និដ្ឋានដដែល ។

- បានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ ព្រាប ឈុន នាពេលសវនាការថា : បានជាខ្ញុំសុំដាក់ពាក្យដកបណ្តឹងសាទុក្ខពីតុលាការកំពូល ព្រោះរឿងក្តីរបស់ខ្ញុំបាទ មានរយៈពេលយូរមកហើយ ។

- បានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅពេលសវនាការថា : ដោយជនជាប់ចោទបានដាក់ពាក្យសុំដកបណ្តឹងសាទុក្ខ ដូច្នេះក្នុងនាមខ្ញុំជាដើមបណ្តឹងរដ្ឋប្បវេណី ពុំមានយោបល់អ្វីជំទាស់ទេ សូមអោយតុលាការធ្វើទៅតាមច្បាប់ចុះ ។

- បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់លោក សុក ផេង ជាមេធាវីការពារអោយជនជាប់ចោទ នៅពេលសវនាការថា : ដោយកូនក្តីរបស់ខ្ញុំបាទបានសុំដកពាក្យបណ្តឹងសាទុក្ខចេញវិញ ក្នុងនាមខ្ញុំបាទជាមេធាវីការពារអោយជនជាប់ចោទ គ្មានយោបល់អ្វីទេ សូមតុលាការមេត្តាសំរេចតាមច្បាប់ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ពាក្យសុំដកបណ្តឹងសាទុក្ខរបស់ឈ្មោះ ព្រាប ឈុន
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៤៩ ចុះថ្ងៃទី ២៧-៥-៩៩ របស់លោក សុក ផេង មេធាវីជនជាប់ចោទ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន តាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ពាក្យបណ្តឹងចុះថ្ងៃទី ២៧-៨-៩៩ របស់ជនជាប់ចោទឈ្មោះ ព្រាប-ឈុន ប្តឹងសុំដកបណ្តឹងសាទុក្ខរបស់ខ្លួនវិញ ដោយមានបញ្ជាក់ពីប្រធានពន្ធនាគារ " តេជោ " មានលក្ខណៈត្រឹមត្រូវតាមច្បាប់ តុលាការកំពូលគប្បីអនុញ្ញាតតាមសុំ ។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្ដីចំពោះមុខជនជាប់ចោទ និង ដើមបណ្ដឹងរដ្ឋប្បវេណី

១ - ទទួលបណ្ដឹងចុះថ្ងៃទី ២៧ - ៨ - ៩៩ របស់ជនជាប់ចោទឈ្មោះ ព្រាប យុន ប្ដឹងសុំដកបណ្ដឹងសាទុក្ខរបស់ខ្លួនវិញ ទុកជាត្រឹមត្រូវតាមច្បាប់ ។

២ - អនុញ្ញាតអោយជនជាប់ចោទឈ្មោះ ព្រាប យុន ដកបណ្ដឹងសាទុក្ខរបស់ខ្លួនវិញតាមសុំ ។

៣ - បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ៥៤ ចុះថ្ងៃទី ១៩ - ៨ - ៩៩ របស់តុលាការកំពូលទៅតុលាការក្រុងភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធី ។

៤ - សាលដីកានេះប្រកាសនាសវនាការ ជាសាធារណៈនៅថ្ងៃទី ២៧ - ១០ - ១៩៩៩ ។